ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង មូលនិធិអភិវឌ្ឍន៍មូលធន នៃអង្គការសហប្រជាជាតិ និងនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា

ថ្ងៃព្រហស្បតិ៍ ៦រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ត្រូវនឹងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នារាត្រីថ្ងៃព្រហស្បតិ៍ ៦រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា **(ន.ម.ក.)** និង ឯកឧត្តម **ហុង សុហួរ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃផ្សារមូលបត្រកម្ពុជា **(ផមក)** និងលោកស្រី **PREETI Sinha** អគ្គលេខាធិការប្រតិបត្តិនៃមូលនិធិអភិវឌ្ឍន៍មូលធននៃអង្គការសហប្រជាជាតិ (UN Capital Development Fund-UNCDF) បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពី **“ការផ្តល់ជំនួយបច្ចេកទេសក្នុងការលើកកម្ពស់ការអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា”** នៅសណ្ឋាគារ សូហ្វី-តែល ភូគីត្រា ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជា។

ការចុះអនុស្សរណៈនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍វិស័យមូលបត្រនៅកម្ពុជា ដែល UNCDF នឹងផ្តល់ការគាំទ្រមក **ន.ម.ក.** និង **ផមក** លើចំណុចរួមមាន÷ ១). គាំទ្រដល់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២). គាំទ្រដល់ការរៀបចំនូវបទប្បញ្ញត្តិថ្មីពាក់ព័ន្ធនឹងផលិតផលមូលបត្រឆ្លងដែន ៣). សម្រួលដល់ការផ្លាស់ប្តូរធនធាន បច្ចេកវិទ្យា និងចំណេះដឹងរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងការរៀនសូត្រពីដៃគូរវាង **ន.ម.ក.** និង **ផមក** ជាមួយនឹងស្ថាប័ននិយ័តកររបស់ប្រទេសសមាជិកអាស៊ានបូក ៣ និង ៤). ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍ ផ្សព្វផ្សាយ និងអនុវត្តច្បាប់ ព្រមទាំងក្របខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្ររដ្ឋ និងមូលបត្រមហាជន។ នាល្ងាចថ្ងៃដដែល **ន.ម.ក. ផមក** និង UNCDF ក៏បានរៀបចំកម្មវិធីរាត្រី

ជួបជុំជាមួយវិនិយោគិន និងអ្នកចូលរួមក្នុងទីផ្សារ ដើម្បីភ្ជាប់ និងបង្កើនកិច្ចសហការជាមួយបណ្ដាញវិនិយោគិនកម្ពុជា និងវិស័យឯកជន។

កម្មវិធីនេះ មានការចូលរួមពីឯកអគ្គរដ្ឋទូត និងតំណាងដ៏ខ្ពង់ខ្ពស់នៃឯកអគ្គរដ្ឋទូត នៃប្រទេសអាស៊ានបូកបី អគ្គនាយក និងថ្នាក់ដឹកនាំនៃនិយ័តករក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនធានាទិញមូលបត្រ ឈ្មួញជើងសារមូលបត្រ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ធនាគារពាណិជ្ជ ក្រុមហ៊ុនធានារ៉ាប់រង និងវិនិយោគិនសក្ដានុពលក្នុងទីផ្សារមូលបត្រ។ កម្មវិធីនេះ បានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កាខ្ពស់។

៳៳❀៴៴